ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០០២ ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី ៦ ខែ07 ឆ្នាំ២០០០

# សារាចរណែនាំ

## ស្តីពី

## ការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់ របស់សហគ្រាស ក្រុមហ៊ុន និង រូបវ័ន្តបុគ្គលបរទេស

យោងមាត្រាទី ១៩ ត្រង់ផ្នែកទី ៤ នៃច្បាប់ស្តីពី "វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម" ដែលចែងពី ក្រុមហ៊ុនបរទេស ដែលមានតែសាខា ឬ ទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា និង យោងតាមប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម របស់បណ្តាសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបរទេសដូចតទៅ :

### I ការកំណត់ទ្រង់ទ្រាយ

សហគ្រាស ក្រុមហ៊ុន រូបវ័ន្តបុគ្គលបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបាន បែងចែកតាមទ្រង់ទ្រាយអាជីវកម្មដូចតទៅ :

១-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣-រូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

### II ការចុះបញ្ជីប្រកបអាជីវកម្ម

ចំពោះ :

១- អភិបាលការិយាល័យតំណាង ឬ ទីភ្នាក់ងារ និង សាខាក្រុមហ៊ុន ឬ អាណត្តិគាហកនៃ សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ទីភ្នាក់ងារ និង សាខាក្នុងព្រះរាជាណាចក្រកម្ពុជា

២- អភិបាល ឬ សមាជិកនៃសហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា

៣- រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះការិយាល័យតំណាងទីភ្នាក់ងារ ឬ សាខាក្រុមហ៊ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង ចុះឈ្មោះសហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ក្នុងបញ្ជីអាជីវកម្ម នៅនាយកដ្ឋានសិក្សាគំរោងប្លង់ចំណុះអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

អភិបាល ឬ អាណត្តិគាហក ត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋានសិក្សាគំរោងប្លង់ ដើម្បីធានាអះអាងទទួលខុសត្រូវលើរាល់សំណុំលិខិត ដែលខ្លួនបានយកមកតម្កល់ទុក នៅនាយកដ្ឋានសិក្សាគំរោងប្លង់ ថាពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ។

ក្នុងករណីដែលពិនិត្យឃើញថា លិខិត ឬ ឯកសារណាមួយនៃសំណុំឯកសារសុំចុះបញ្ជីប្រកបអាជីវកម្មមានភាពមិនច្បាស់លាស់ អភិបាលការិយាល័យតំណាង ទីភ្នាក់ងារ សាខាក្រុមហ៊ុន ឬ ប្រធានក្រុមប្រឹក្សាអភិបាលក្រុមហ៊ុន ឬ អភិបាលណាម្នាក់ ឬ អាណត្តិគាហក ត្រូវមកបំភ្លឺ និង ដោះស្រាយទៅតាមករណីនីមួយៗតាមការកោះអញ្ជើញរបស់ប្រធាននាយកដ្ឋានសិក្សាគំរោងប្លង់ ។

កាលបើពិនិត្យឃើញថា សំណុំលិខិត និង ពតិមានមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវតាមការណែនាំ (បញ្ញត្តិ ) ហើយនោះមន្ត្រីចុះបញ្ជីនៅនាយកដ្ឋានសិក្សាគំរោងប្លង់ត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្ម ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នឹងប្រគល់ជូនវិញ្ញាបនប័ត្រ និង ប្រកាស ដែលអនុញ្ញាតអោយប្រកបអាជីវកម្មដល់អ្នកស្នើសុំក្នុងរយៈពេលយ៉ាងយូរមិនអោយហួសពី ១ខែ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំ ដែលមានលក្ខណៈត្រឹមត្រូវ និង គ្រប់គ្រាន់។

III ប្រភេទ សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់

១-១- សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា

ក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចសេចក្តីប្រកាស លេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគំរោងប្លង់នៃសាមីដើមប្រទេស

២-ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និង ក្រុមហ៊ុន របស់សាមីដើមប្រទេស។

១-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានការិយាល័យតំណាង ឬ ទីភ្នាក់ងារ

និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ ក្នុងប្រការ ៣ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់របស់សាមីដើមប្រទេស

២-ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និង ក្រុមហ៊ុនរបស់សាមីដើមប្រទេស ។

២-១ សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុនបានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ គ ក្នុងប្រការ២ ។

២-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន សាងសង់បានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ចំណុច ក ខ គ ក្នុង ប្រការ ៣ ។

៣-១- រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ត្រង់ចំណុច ឃ១ ឃ២ ឃ៣ ឃ៤ ឃ៥ ក្នុងប្រការ២ ។

## IV ទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់

ទំរង់បែបបទសុំប្រកបអាជីវកម្ម មានលក្ខខ័ណ្ឌកំណត់ដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ប៉ុន្តែចំពោះ :

១- នាយកបច្ចេកទេស នាយកគំរោង និង អ្នកបច្ចេកទេសនៃសហគ្រាស ក្រុមហ៊ុនបរទេសដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ជាតិ បរទេស ឬ ខ្មែរ

២- ការអនុវត្តការងារសិក្សាគំរោងប្លង់ និង សាងសង់ត្រូវអនុវត្តតាមលិខិតបទដ្ឋានបច្ចេកទេសរបស់ព្រះរាជាណាចក្រកម្ពុជា ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ និងតាមភារកិច្ចរៀងៗខ្លួនដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់

រដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ